# ១៦.ព្រេងទាក់ទងនឹងទឹកជោរទឹកនាច

តាមពង្សាវតាររបារក្សត្រខ្មែរថា កាលនៅក្នុងរាជ្យព្រះបាទសេនកករាជ (គ.ស. ១២៣៨ -១២៥៥) ដែលសោយរាជ្យនៅមហានគរ ព្រះអង្គមានព្រះរាជបុត្រាមួយអង្គ ចូលចិត្តលេងចិញ្ចឹមរុយខៀវ ។ មានកូនមហាតលិកមួយ ចូលចិត្តចិញ្ចឹមពីងពាង ។

ថ្ងៃមួយ ព្រះរាជកុមារ យករុយមកដាក់ជាមួយនឹងពីងពាង ពីងពាងនោះខាំរុយស្លាប់ទៅ ។ ព្រះរាជកុមារទ្រង់ព្រះកន្សែង ភីលៀងលួងដូចម្តេច ក៏មិនបាត់ ទើបជ្រាបទៅដល់ព្រះបិតា ។ ព្រះបិតាទ្រង់ខ្ញាល់ ឲ្យចាប់កូនមហាតលិកយកទៅជាន់ជ្រមុជទឹកក្នុងទន្លេសាបស្លាប់ទៅ ។

ឯស្តេចភុជង្គនាគ ដែលបានស្រូបទឹកឲ្យគោកទៅជាដីនគរដោយស្តេចកុមេរុរាជជាបឋមមហាក្សត្រខ្មែរ ហើយដែលបានសន្យានឹងស្តេចនោះថា នឹងជួយយកភាសានគរនេះរហូតទៅនោះ លុះដឹងថា ព្រះបាទសេនកករាជ សម្លាប់មនុស្សឥតពិចារណា ក៏ប្រើរេហ៍ពលឲ្យក្អែទឹកសម្តែងរឹទ្ធិឲ្យទឹកជោរជន់លិចនគរ ជាកោលាហល ។ លុះទឹកទឹកនោះជោរជន់លិចនគរហើយ ពួករេហ៍ពលនាគ ក៏ឈប់ក្អែទឹកទៀតទើបទឹកនោះនាចស្រកថយមកវិញ ។

អាស្រ័យមហិទ្ធិឫទ្ធិឥទ្ធិពល របស់ពួកនាគ ដែលបានសម្តែងមកនេះ ទើបទឹកជោរទឹកនាច ចេះតែមានរៀងរាបមកជាធម្មតា ។

រឿងបូជានេះ យូរទៅ លុះអស់អំពីនាងយក្ខិនីទៅ ក៏ក្លាយទៅជាទំនៀមបូជាព្រះភូមិ ដើម្បីឲ្យធ្វើស្រូវបាន ផលច្រើនទៅវិញ ។